ទម្រង់ទី៣៣

# សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ
# សម្រាប់កិច្ចសន្យាការងារសាងសង់របស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រោមក្របខ័ណ្ឌគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប

Loan/Grant 2599/0186-CAM: Tonle Sap Poverty Reduction and Smallholder Development Project

| រាជធានី ខេត្ត ៖ *ត្បូងឃ្មុំ* | ក្រុង ស្រុក ខណ្ឌ ៖ *តំបែរ* | ឃុំ សង្កាត់ ៖ *សេដា* |
|---|---|---|

- ការពិពណ៌នាអំពីលទ្ធផលកិច្ចសន្យា ៖
  - ការសាងសង់ ៖ *ជួសជុលផ្លូវក្រាលក្រួសក្រហម៥ខ្សែប្រវែង ៣.៣៥៤ គ.ម និង ស្លាកសញ្ញាគម្រោង១កន្លែង។*
  - រយៈពេលថែទាំ ៖ *រយៈពេល៦ ខែ*

| | |
|---|---|
| តម្លៃប៉ាន់ស្មាន | *USD ៣៨,២៥៨.១៤ (សាមសិបប្រាំបីពាន់ពីររយហាសិបប្រាំបីដុល្លាអាមេរិក និងដប់បួនសេន)* |
| អ្នកដែលអាចដេញថ្លៃ | *អ្នកទទួលការ ប្រភេទទី២* |
| ប្រាក់កក់ធានាការដេញថ្លៃ | *យ៉ាងតិច USD ៧៦៦.០០(ប្រាំពីររយហុកសិបប្រាំមួយដុល្លាអាមេរិកគត់)* |
| ឈ្មោះធនាគារពាណិជ្ជដែលត្រូវតម្កល់ប្រាក់កក់ | *ធនាគារពាណិជ្ជណាមួយ* |
| រយៈពេលសុពលភាពនៃសំណើដេញថ្លៃ | *ចំនួន៤៥(សែសិបប្រាំ)ថ្ងៃ ចាប់ពីថ្ងៃប្រជុំបើកសំណើដេញថ្លៃ* |
| ទីកន្លែងដែលអាចទទួលឯកសារដេញថ្លៃ | *នៅសាលាឃុំសេដា ឬនៅទីចាត់ការផែនការនិងវិនិយោគខេត្ត ឬគេហទំព័រនៃលេខាធិការដ្ឋាន គ.ជ.អ.ប/NCDDS 1* |
| ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ | *សាលាឃុំ សេដា* |
| កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ | *ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៦* |
| • ពេលវេលាចាប់ផ្តើមទទួលសំណើដេញថ្លៃ | *ម៉ោង ០៨:៣០ ព្រឹក* |
| • ពេលវេលាឈប់ទទួលសំណើដេញថ្លៃ | *ម៉ោង ០៨:៤០ ព្រឹក* |
| • ពេលវេលាបើកសំណើដេញថ្លៃ | *ម៉ោង ០៨:៤០ ព្រឹក* |

**កំណត់សម្គាល់ ៖**

- ឯកសារដេញថ្លៃត្រូវភ្ជាប់មកជាមួយនូវប័ណ្ណធានាការដេញថ្លៃដោយប្រើទម្រង់ធានាការដេញថ្លៃ ( ទម្រង់លិខិតធានារបស់ធនាគារ ) ដូចមានភ្ជាប់នៅក្នុងឯកសារដេញថ្លៃនេះ ដោយមានទឹកប្រាក់កក់ធានាដូចបានកំណត់ខាងលើ ។
- ក្នុងរយៈពេល១៤ថ្ងៃបន្ទាប់ពីទទួលបានដំណឹងផ្តល់កិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវផ្តល់ប្រាក់កក់ធានាការអនុវត្តក្នុងទម្រង់ជាប័ណ្ណធានារបស់ធនាគារចំនួន១០ភាគរយនៃតម្លៃកិច្ចសន្យា។ ការបរាជ័យក្នុងការអនុវត្តចំណុចខាងលើនេះគឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់លុបចោលនៃការផ្តល់កិច្ចសន្យា និងរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។ ការធានាការអនុវត្តត្រូវមានសុពលភាពរហូតដល់រយៈពេល ៣០ថ្ងៃ បន្ទាប់ពីចេញរបាយការណ៍បញ្ចប់ការងារ១០០ភាគរយ ។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយ ប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។

ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៦

**មេឃុំ ចៅសង្កាត់**

**មុំ ស៊ីថា**

ទម្រង់ទី៣៦

# សំណើដេញថ្លៃ

## សម្រាប់កិច្ចសន្យាការងារសាងសង់របស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រោមក្របខ័ណ្ឌគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប

Loan/Grant 2599/0186-CAM: Tonle Sap Poverty Reduction and Smallholder Development Project

| | | |
|---|---|---|
| រាជធានី ខេត្ត ៖ *ត្បូងឃ្មុំ* | ក្រុង ស្រុក ខណ្ឌ ៖ *តំបែរ* | ឃុំ សង្កាត់ ៖ *សេដា* |

ឈ្មោះគម្រោង ៖ *ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ៣.៣៥៤ គ.ម*

| | | |
|---|---|---|
| ឈ្មោះអ្នកដេញថ្លៃ ៖ | ឈ្មោះក្រុមហ៊ុន ៖ | លេខអត្តសញ្ញាណប័ណ្ណ ៖ |

| ល.រ | ការពិពណ៌នា | ភូមិ | បរិមាណ | ឯកតា | តម្លៃឯកតា ($) | តម្លៃសរុប ($) |
|---|---|---|---|---|---|---|
| *១* | *ជួសជុលផ្លូវក្រាលក្រួសក្រហម ទទឹង៤ម* | *កំពង់រាំង* | *0.៩៥០* | *គ.ម* | | |
| *២* | *ជួសជុលផ្លូវក្រាលក្រួសក្រហម ទទឹង៤ម* | *កំពង់រាំង* | *0.១៨៥* | *គ.ម* | | |
| *៣* | *ជួសជុលផ្លូវក្រាលក្រួសក្រហម ទទឹង៤ម* | *កំពង់រាំង* | *0.២៦៩* | *គ.ម* | | |
| *៤* | *ជួសជុលផ្លូវក្រាលក្រួសក្រហម ទទឹង៤ម* | *កំពង់រាំង* | *0.៨00* | *គ.ម* | | |
| *៥* | *ជួសជុលផ្លូវក្រាលក្រួសក្រហម ទទឹង៤ម* | *កំពង់រាំង* | *១.១៥0* | *គ.ម* | | |
| | | | | | | |
| **សរុបតម្លៃដាក់ដេញ** | | | | | | |

(តម្លៃដាក់ដេញសរុបជាអក្សរ.....................................................................................................................)។

- ខ្ញុំជាអ្នកដេញថ្លៃបានអាន និងយល់ច្បាស់អំពីកិច្ចសន្យា គំនូសប្លង់ និងសេចក្តីលម្អិតបច្ចេកទេស។ ខ្ញុំបានយល់ព្រមសាងសង់ទៅតាមកិច្ចសន្យា និងពេលវេលាដែលបានកំណត់។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។
- កំហុសមួយចំនួនអាចត្រូវបានកែតម្រូវដោយគណៈកម្មការលទ្ធកម្ម។ ប្រសិនបើអ្នកដេញថ្លៃមិនទទួលយកការកែតម្រូវនេះទេ គណៈកម្មការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនេះ ដោយចាត់ទុកថា ជាសំណើដេញថ្លៃដែលមិនមានសុពលភាព។

**កំណត់សម្គាល់ ៖** សំណើដេញថ្លៃនេះមានសុពលភាពរយៈពេល **៤៥ថ្ងៃ** ចាប់ពីកាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ។

ថ្ងៃទី....... ខែ........... ឆ្នាំ........

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

ទម្រង់ទី៣៩

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសស្តីពី
# ក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ

ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញសូមប្រកាសអះអាងដូចខាងក្រោម ÷

១. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានទំនាក់ទំនងណាមួយដែលជាទំនាស់ផលប្រយោជន៍ដែលបានចែងនៅក្នុងឯកសារដេញថ្លៃ ។

២. បើយើងខ្ញុំបានដឹងអំពីទំនាស់ផលប្រយោជន៍ទាំងនេះ យើងខ្ញុំនឹងរាយការណ៍ភ្លាមជូនទៅគណៈកម្មការលទ្ធកម្ម ឃុំ សង្កាត់ អភិបាលខេត្ត ក្រុង និងក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ។

៣. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ បង្គាប់បញ្ជា និងឃុបឃិតស៊ីគ្រលំចំពោះការដាក់សំណើដេញថ្លៃរបស់ខ្ញុំឡើយ ។

៤. យើងខ្ញុំបានដឹងច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវអនុញ្ញាតឱ្យរដ្ឋាភិបាល និងឬទីភ្នាក់ងារផ្តល់មូលនិធិ ធ្វើការត្រួតពិនិត្យនូវរាល់ឯកសារនានាដែលទាក់ទងនឹងការរៀបចំសំណើដេញថ្លៃរបស់យើងខ្ញុំ និងកិច្ចសន្យាណាមួយដែលអាចជាលទ្ធផលពីភាពមិនប្រក្រតីដែលគិតស្មានមិនដល់ ទោះបីជាកិច្ចសន្យានោះយើងខ្ញុំឈ្នះ ឬចាញ់ក៏ដោយ ។

៥. នៅក្នុងដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្ម និងកិច្ចសន្យាណាមួយដែលឈ្នះក្នុងការដេញថ្លៃនេះ ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានចំណាយប្រាក់ ឬផ្តល់ជូនជាសារគុណឱ្យទៅបុគ្គលិក ទីប្រឹក្សា អ្នកសហការ ឬសាច់ញាតិនៃអ្នកដែលពាក់ព័ន្ធនៅក្នុងដំណើរការលទ្ធកម្ម ការអនុវត្តគម្រោង និងការចេញអាណត្តិទូទាត់ ។

ក្នុងករណីមិនគោរពតាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ ទំនិញនឹងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ។

ថ្ងៃទី------ ខែ--------- ឆ្នាំ------

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ
ធនាគារ.............
លេខ..................

# លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**
**លោក លោកស្រីមេឃុំ ចៅសង្កាត់** *សេដា*

ដោយហេតុថាក្រុមហ៊ុន.....................

មានបំណងដាក់ពាក្យសុំដេញថ្លៃកិច្ចសន្យា *គម្រោងជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ៣.៣៥៤គ.ម* របស់ឃុំ សង្កាត់ *សេដា* ដែលនឹងត្រូវប្រជុំបើកសំណើដេញថ្លៃនៅ ថ្ងៃទី *២៧ ខែកក្កដា ឆ្នាំ២០១៦* តាមសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់កិច្ចសន្យារបស់ក្រុមប្រឹក្សាឃុំសង្កាត់ *សេដា* ចុះថ្ងៃទី *១២ ខែកក្កដា ឆ្នាំ២០១៦*។

យើងខ្ញុំសូមធានា និងទទួលខុសត្រូវចំពោះលោក លោកស្រីមេឃុំ ចៅសង្កាត់ *សេដា* នូវប្រាក់កក់ធានាការដេញថ្លៃចំនួន *USD ៧៦៦.00* (ជាអក្សរ *ប្រាំពីររយហុកសិបប្រាំមួយដុល្លាអាមេរិកគត់)* ។

ក្នុងករណីមានល័ក្ខខ័ណ្ឌណាមួយកើតមានឡើងក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីខាងក្រោម ៖

1. ប្រសិនបើអ្នកដេញថ្លៃដកពាក្យរបស់ខ្លួនក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
2. ប្រសិនបើអ្នកដេញថ្លៃមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
3. ប្រសិនបើអ្នកដេញថ្លៃមិនព្រមកក់ប្រាក់ធានាការអនុវត្ត។

នោះធនាគារយើងខ្ញុំនឹងធ្វើការផ្ទេរបង្វែរចូលថវិការដ្ឋនូវចំនួនប្រាក់ខាងលើ នៅពេលដែលបានទទួលពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សរពីលោក លោកស្រីមេឃុំ ចៅសង្កាត់ *សេដា ។*

លិខិតធានានេះនឹងផុតកំណត់:

ក) ប្រសិនបើអ្នកដេញថ្លៃគឺជាអ្នកដេញថ្លៃឈ្នះទទួលបានការបញ្ជាក់ថាបានចុះកិច្ចសន្យាដោយអ្នកដេញថ្លៃ និងបានចេញលិខិតធានាការអនុវត្ត។

ខ) ប្រសិនបើអ្នកដេញថ្លៃមិនបានជោគជ័យ:

១) បង្ហាញឯកសារច្បាប់ចតចម្លងនៃកិច្ចសន្យារបស់អ្នកដេញថ្លៃឈ្នះឬ

២) រយៈពេល៣០ថ្ងៃបន្ទាប់ពីផុតកំណត់នៃសុពលភាពដេញថ្លៃ។

ធ្វើនៅ.................. ថ្ងៃទី....... ខែ............ ឆ្នាំ.........

**នាយកធនាគារ**

ទម្រង់ទី ១៤

## លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ (សិក្សា)

| ខេត្ត ក្រុង: ត្បូងឃ្មុំ | | ស្រុក ខណ្ឌ : តំបែរ | ឃុំ សង្កាត់ : សេដា | | | ឈ្មោះគម្រោង : ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ៣.៣៥៤ គ.ម | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| លរ | ឈ្មោះភូមិ | លេខលទ្ធផល | ការពិពណ៌នាអំពីលទ្ធផល | ថ្មី ឬ ជួសជុល ឬ កែលម្អ | តាមប្លង់ គំរូ (បាទ ឬទេ) | បរិមាណ | ឯកតា | ស្តង់ដារទំហំ១ | | ស្តង់ដារទំហំ២ | | តម្លៃប៉ាន់ស្មាន | |
| | | | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | សរុប |
| ១ | កំពង់រាំង | ១០១០១០២ | ផ្លូវក្រួសក្រហម | ជួសជុល | បាទ | 0.950 | គ.ម | ទទឹង | 4m | មាឌដី | 2936.77$m^3$ | | |
| ២ | កំពង់រាំង | ១០១០១០២ | ផ្លូវក្រួសក្រហម | ជួសជុល | បាទ | 0.185 | គ.ម | ទទឹង | 4m | មាឌដី | 579.84$m^3$ | | |
| ៣ | កំពង់រាំង | ១០១០១០២ | ផ្លូវក្រួសក្រហម | ជួសជុល | បាទ | 0.269 | គ.ម | ទទឹង | 4m | មាឌដី | 816.41$m^3$ | | |
| ៤ | កំពង់រាំង | ១០១០១០២ | ផ្លូវក្រួសក្រហម | ជួសជុល | បាទ | 0.800 | គ.ម | ទទឹង | 4m | មាឌដី | 2418.32$m^3$ | | |
| ៥ | កំពង់រាំង | ១០១០១០២ | ផ្លូវក្រួសក្រហម | ជួសជុល | បាទ | 1.150 | គ.ម | ទទឹង | 4m | មាឌដី | 84607.44$m^3$ | | |
| **តម្លៃប៉ាន់ស្មានសរុបនៃគម្រោង** | | | | | | | | | | | | | |

**កំណត់សម្គាល់៖** មានតែលទ្ធផលគម្រោងដែលថវិកាគ្រប់គ្រាន់ប៉ុណ្ណោះ ត្រូវបានកត់ត្រាក្នុងទម្រង់នេះ។

*ថ្ងៃទី------ ខែ--------ឆ្នាំ-------*

**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី------ ខែ--------- ឆ្នាំ-------*

**អ្នកជំនួយបច្ចេកទេស**